ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល
វិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ ១០ សកបម

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ១៩៩៩

# ប្រកាស
## ស្តីពី
## ប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាស ថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការងារដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស-រកម-០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៧
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត ១១៩៨. ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

## <u>សំរេច</u>

<u>ប្រការ១</u>: ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាសដូចមានចែងក្នុងមាត្រា១ នៃច្បាប់ ស្តីពីការងារ ត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតរបស់ខ្លួនបានឈប់សំរាកដោយមានប្រាក់ឈ្នួលក្នុងឱកាសថ្ងៃឈប់បុណ្យ ដែលកំណត់ជារៀងរាល់ឆ្នាំ ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

**ប្រការ២:** ក្នុងករណីចាំបាច់ ដែលគ្រឹះស្ថាន ឬ សហគ្រាសមិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសថ្ងៃឈប់បុណ្យដូចមានចែងក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាសអាចសំរបសំរួលជាមួយកម្មករ និយោជិតរបស់ខ្លួនអោយធ្វើការនៅថ្ងៃឈប់បុណ្យទាំងនេះបាន ។

**ប្រការ៣:** ការធ្វើការថ្ងៃបុណ្យត្រូវមានការស្ម័គ្រចិត្តពីកម្មករ និយោជិត ។

**ប្រការ៤:** កម្មករ និយោជិតដែលធ្វើការថ្ងៃឈប់បុណ្យ មានសិទ្ធិទទួលនូវប្រាក់បំណាច់មួយដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា ។

ឧទាហរណ៍ ១: និយោជិត ម្នាក់មានប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែ ៥២ដុល្លារ ក្នុងមួយខែ ។ នៅថ្ងៃ ៨ មិនាជាថ្ងៃឈប់បុណ្យ មានប្រាក់ឈ្នួលនិយោជិតនោះគាត់ស្ម័គ្រចិត្តមកធ្វើការតាមសំណូមពររបស់និយោជកពេញ១ថ្ងៃធ្វើការ ។ ក្នុងករណីនេះដល់ពេលបើកប្រាក់ឈ្នួលគាត់ត្រូវទទួលបាន $= 52\$ + (\frac{52\$}{26} \times 1) = 54\$$ ។

ឧទាហរណ៍ ២: និយោជិតម្នាក់ទៀតមានប្រាក់ឈ្នួលសុទ្ធសាធ 52 $\$$ ក្នុងមួយខែ ។ នៅថ្ងៃ ៨ មិនាជាថ្ងៃឈប់បុណ្យ មានប្រាក់ឈ្នួលនិយោជិតនោះគាត់ស្ម័គ្រចិត្តមកធ្វើការចំនួន៤ម៉ោងតាមសំណូមពររបស់និយោជក។ ថិរវេលាធ្វើការរបស់សហគ្រាសនោះ គឺ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ។ ក្នុងករណីនេះដល់ពេលបើកប្រាក់ឈ្នួលគាត់ត្រូវទទួលបាន $= 52\$ + [(\frac{52\$ \times 12}{52 \times 48}) \times 4] = 53\$$ ។

**ប្រការ៥:** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៧៧ សកអ ចុះថ្ងៃទី ១៩ -២- ៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦:** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង "ដើម្បី ជ្រាប"
- ក្រសួងពត៌មាន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍
- រាជកិច្ច
- គ្រប់អធិការដ្ឋានសង្គមកិច្ច ខេត្ត-ក្រុង "ដើម្បីជ្រាប"
- បិទផ្សាយនៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នាយកដ្ឋានអធិការកិច្ចការងារ និងអធិការដ្ឋានសង្គមកិច្ច ខេត្ត-ក្រុង
- កាលប្បវត្តិ និងឯកសារ